# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីបុណ្យទក្ខិណានុប្បទានដែលមានសំដែង
## ក្នុងព្រះពុទ្ធសាសនា

**web site: hoksavann.org**

ថ្ងៃទី២៥ តុលា ២០០៥

បុណ្យទក្ខិណានុប្បទានជាបុណ្យមួយធ្វើឡើងដើម្បីឧទ្ទិសកុសលជូនដល់អ្នកដែលចែកឋានទៅ ។ តាមធម្មតា មនុស្សណាម្នាក់មានបំណងជូនវត្ថុដល់អ្នកណាម្នាក់ គេអាចជូនដោយវាចា ឬដោយហុចជូនដោយផ្ទាល់ដៃក៏បាន ប៉ុន្តែចំពោះអ្នកដែលស្លាប់ទៅពុំអាចជូនបែបនេះបានឡើយ គឺត្រូវបុណ្យកុសល មានធ្វើទាន សមាទានសីលជាដើមហើយ តាំងចិត្តជូនទៅ ដែលហៅថាទក្ខិណានុប្បទាននេះឯង ។ បុណ្យទក្ខិណានុប្បទាននេះត្រូវធ្វើឲ្យត្រឹមត្រូវ ទើបសំរេចផលដល់អ្នកដែលចែកឋានទៅ ដោយអង្គបីប្រការគឺ ១- ត្រូវធ្វើបុណ្យកុសល មានការធ្វើទានរក្សាសីលភាវនាជាដើម ជាពិសេសត្រូវធ្វើទាន ចំពោះអ្នកមានសីល ដែលក្នុងបាលីថា សង្ឃម្ហិ សុបតិដ្ឋិតា ប្រែថាទានបានដំកល់ល្អ ហើយក្នុងព្រះសង្ឃ ។ ២- ឧទ្ទិសេន ប្រែថាដោយការជូនកុសលទៅ ។ បានសេចក្តីថា ត្រូវតាំងចិត្តឧទ្ទិសកុសល ដែលបានធ្វើនោះ ជូនដល់អ្នកដែលចែកស្ថានទៅ ទើបអ្នកស្លាប់មានសិទ្ធិទទួល ។ បើពុំបានឧទ្ទិសជូនទៅទេ អ្នកស្លាប់គ្មានសិទ្ធិទទួលឡើយ ប្រៀបដូចជនណាម្នាក់ពុំហ៊ានយកវត្ថុដែលគេពុំបានឲ្យដោយកាយឬដោយវាចា បើយកទុកជាបទលួច ។ ការឧទ្ទិសកុសល គឺឧទ្ទិសតាមមនោទ្វារ គឺផ្លូវចិត្តទុកជាបានការ ។ បើបញ្ចេញវាចាដូចជាធម៌វេរថែមទៀត ក៏រឹតតែល្អ ឯអ្នកខ្លះសរសេរឈ្មោះអ្នកស្លាប់ ព្រោះខ្លាចភ្លេចនឹកពុំអស់ ។ ៣- អនុមោទនេន គឺអ្នកស្លាប់ដែលបានទៅកើតជាអ្វីមួយនោះ អាចទទួលត្រេកអរបានផង ។ ក្នុងតិរោកុឌ្ឌសូត្របញ្ជាក់ថា សត្វដែលអាចទទួលផលដែលញាតិមិត្តឧទ្ទិសទៅឲ្យភាគច្រើន បានដល់ប្រេត ពពួកមានប្រេតឈ្មោះបរទត្តុបជីវីប្រេត ដែលប្រែថា ប្រេតរស់នៅដោយសារអំណោយផល ដែលញាតិមិត្តឧទ្ទិសទៅឲ្យជាដើម នេះជាអង្គ៣យ៉ាងនៃការធ្វើបុណ្យទក្ខិណានុប្បទាន ។ មានទំនៀមទំលាប់ក្រៅ

ពុទ្ធសាសនាមួយ គឺការសែនព្រេនដោយរៀបចំបាយទឹកនំចំណី ហើយនិយាយអញ្ជើញអ្នកដែលចែកស្ថានទៅ ឲ្យមកសេពសោយ ។ តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ការសែនបែបនេះ អ្នកដែលស្លាប់ទៅពុំអាចមកបរិភោគភោជនាហារនោះបានឡើយ ព្រោះអ្នកស្លាប់ទៅបានទៅកើតជាអ្វីមួយ មានអាហារផ្សេងៗគ្នា ប៉ុន្តែបានផលដល់អ្នកធ្វើខ្លះ ត្រង់នឹកគុណដល់អ្នកស្លាប់ ។

ចំណែកព្រះសង្ឃស្វូត្រធម៌ធម្មសង្វេគ ដែលពុទ្ធបរិស័ទនិយមហៅថាធម៌បង្សុកូលនោះ គ្រាន់តែជាកិច្ចអនុមោទនាទៅលើអង្គទាំង៣នៃទក្ខិណានុប្បទាននោះប៉ុណ្ណោះ ។ តាមពិត ការស្វូត្រធម៌ធម្មសំវេគដែលហៅថាធម៌បង្សុកូលនោះ មានគោលបំណងពិសេសឲ្យអ្នកនៅរស់ដែលជាសមាជិកគ្រួសាររបស់អ្នកស្លាប់ ឲ្យឃើញភាពពុំទៀងនៃជីវិត ដូចព្រះសង្ឃស្វូត្រធម៌អនិច្ចា វត សង្ខារា ប្រែថាសង្ខារទាំងឡាយពុំទៀងមានពិត មានកិរិយាកើតឡើងហើយ វិនាសទៅវិញជាធម្មតា លុះតែរលត់នូវសង្ខារទាំងឡាយនោះហើយ ទើបបាននូវសេចក្តីសុខគ្រប់យ៉ាង ។ សង្ខារក្នុងធម៌នេះ សំដៅយកខន្ធ៥របស់មនុស្សសត្វ ។ អ្នកដែលបានធ្វើបុណ្យឧទ្ទិសទៅនេះរមែងមានចិត្តជ្រះថ្លា នៅពេលធ្វើបុណ្យ ហើយបានបុណ្យម្យ៉ាងទៀត គឺត្រង់នឹកដល់គុណអ្នកដែលចែកស្ថានទៅ ។ ក្នុងខទី៥នៃធម៌ដែលបុត្តធីតាប្រុសស្រី ត្រូវតបគុណចំពោះមាតាបិតាថា បន្ទាប់ពីមាតាបិតាអនិច្ចកម្មទៅ បុត្រធីតាប្រុសស្រីត្រូវធ្វើបុណ្យទក្ខិណានុប្បទានឧទ្ទិសកុសកជូនគាត់ ។ ចំណែកសមាជិកគ្រួសារដែលស្លាប់ទៅ ក្រៅពីមាតាបិតា ក៏ក្រុមគ្រួសារត្រូវឧទ្ទិសកុសលជូនទៅដូចគ្នា ។ ការឧទ្ទិកុសលនេះមិនត្រឹមតែញាតិមិត្តរបស់ខ្លួនទើបឧទ្ទិសកុសលនោះទេ ត្រូវក្រាលចិត្តឲ្យទូលាយឧទ្ទិសទៅគ្រប់សព្វសត្វទាំងអស់ ដូចការស្វូត្រធម៌ យំ កិញ្ចិ គឺជាការឧទ្ទិសកុសលចំពោះសព្វសត្វទាំងអស់ក្នុងទិសទាំង១០ ។ ការឧទ្ទិសកុសលនេះក្នុងឧត្តមគតិថា ទោះបីក្រុមគ្រួសារស្លាប់ទៅហើយ ក៏នៅតែនឹករលឹកគុណពុំភ្លេចហើយជាការជួយសង្គ្រោះក្រែងអ្នកស្លាប់ទៅនោះ ទទួលរងទុក្ខវេទនាក្នុងភាពណាមួយ ៚

៚ ៚

៚